- ធ្វើរបាយការណ៍លំអិតជូនរាជរដ្ឋាភិបាលអំពីលទ្ធផលការងារដែលអនុវត្តបាន និង ស្នើសុំយោបល់សំរេចពី រាជរដ្ឋាភិបាលក្នុងករណីមានចាំបាច់ ។

**ប្រការ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងប៉េកាំង និងសមាសភាពដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេច នេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

---

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០១

## សេចក្តីសំរេចលេខ១៤ សសរ

## ស្តីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាលកម្ពុជា

~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១ :** ត្រូវផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយក រដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋកូរ៉េ ចាប់ពីថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០១ រហូតដល់សម្តេចនាយក រដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

www.pheakdeylaw.com
~~~

ប្រការ២ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និង ឯកឧត្តម ស. ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

## III- ការងារបណ្តាក្រសួង

## ធនាគារជាតិនៃកម្ពុជា

## ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០១

**ប្រកាសលេខ ធ.១.០១.៦៧.ប្រក**

**ស្តីពី**

**ចេនាសម្ព័ន្ធរបស់នាយកដ្ឋានប្រតិបត្តិការ**

**និង មុខងារ ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ**

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

~~~

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៦ ដែលបា នអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ ធនាគាជាតិនៃកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខៈ ជស/រកត / ០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែមិនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងឯកឧត្តម ជា. ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- យោងតាមប្រកាសលេខ :ធ៨៩៨-៣៨៥ប្រក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៨ ស្តីពីរចនាសម្ព័ន្ធ ធនាគារជាតិនៃកម្ពុជា និង មុខងារ-ភារកិច្ចរបស់អង្គភាពក្រោមឱវាទ

- យោងតាមការអនុមតិរបស់អង្គប្រជុំក្រុមប្រឹក្សាភិបាលធនាគាជាតិនៃកម្ពុជា ថ្ងៃទី ២៩ ខែ មិនាឆ្នាំ២០០១

www.pheakdeylaw.com
~~~